E137

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 07 / AUG / 2009
ម៉ោង (Time/Heure): 12:00
[redacted]/Case File Officer/L'agent chargé du do[redacted] C1 Fuy

## សេចក្តីលម្អិតនៃការដាក់ឯកសារ

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០១/១៨-០៧-២០០៧-អវតក/អជសដ |
| កាលបរិច្ឆេទ | : | ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ |
| ភាគីដាក់ជូនសារណា | : | មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី- ក្រុម១ |
| ដាក់ជូន | : | អង្គជំនុំជម្រះសាលាដំបូង |
| ភាសាដើម | : | ភាសាអង់គ្លេស |

**ចំណាត់ថ្នាក់**

| | | |
|---|---|---|
| ចំណាត់ថ្នាក់ឯកសារដែលស្នើសុំដោយភាគីដាក់ឯកសារ | : | សាធារណៈ |
| ចំណាត់ថ្នាក់ដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ | : | |
| ស្ថានភាពចំណាត់ថ្នាក់ | : | |
| ការពិនិត្យឡើងវិញលើចំណាត់ថ្នាក់បណ្តោះអាសន្ន | : | |
| ឈ្មោះមន្ត្រីកត់ត្រា | : | |
| ហត្ថលេខា | : | |

# ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ -- សំណើសុំបញ្ចូលស្ថានភាពរបស់លោក លី ហ៊រ ជាអ្នកនៅរស់រានមានជីវិតពីមន្ទីរ ស-២១ និងយថាភាពនៃឯកសារនានា ជាផ្នែកនៃកំណត់ហេតុ

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 10 / 08 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

E137

**ដាក់ជូនដោយ:**

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**

លោក Karim A.A. KHAN

កញ្ញា ទី ស្រ៊ីនណា

លោក Alain WERNER

លោកស្រី Brianne McGONIGLE

**ជួយរៀបចំដោយ:**

លោកស្រី Daniella RUDY

លោកស្រី Adam BOND

**ចម្លងជូន:**

**ជនជាប់ចោទ:**

លោក កាំង ហ្គេកអ៊ាវ ហៅ "ឌុច"

**សហមេធាវីការពារក្តីជនជាប់ចោទ:**

លោក ការ សាវុត្ថ

លោក François ROUX

**ការិយាល័យសហព្រះរាជអាជ្ញា:**

លោកស្រី ជាលាង

លោក Robert PETIT

លោក យ៉េត ចរិយា

លោក William SMITH

លោក ពេជ្រ សម្បត្តិ

លោក Alex BATES

**ជូនចំពោះ:**

**អង្គជំនុំជម្រះសាលាដំបូង:**

ចៅក្រម **និល ណុន** ជាប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម **យ៉ា សុខន**

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម **ធូ មណី**

**មេធាវីតំណាងដើមបណ្តឹង រដ្ឋប្បវេណី:**

លោក គីម ម៉េងឃី

កញ្ញា ម៉ុច សុវណ្ណារី

លោកស្រី Martine JACQUIN

លោក Philippe CANONNE

លោក គង់ ពិសី

លោក ហុង គីមសួន

លោក យុង ផានិត

លោកស្រី Silke STUDZINSKY

លោក Pirre-Olivier SUR

## I. សេចក្តីផ្តើម

១. កាលពីថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៩ លោក លី ហ៊រ (Ly Hor) ហៅ អ៊ា ហ៊រ (Ear Hor) បានចូលខ្លួនមកតុលាការ ដើម្បីផ្តល់សក្ខីកម្មអំពីពេលវេលាដែលគាត់បានជាប់ឃុំ នៅមន្ទីរ ស-២១ ក្នុងនាមគាត់ជាអ្នកទោសមួយរូប។ ផ្អែកតាមភាពមិនស៊ីសង្វាក់គ្នា ដែលបង្ហាញឲ្យឃើញនៅក្នុងការផ្តល់សក្ខីកម្មរបស់គាត់ ភាពមន្ទិលសង្ស័យបានកើតមានឡើងចំពោះការពិតនិងសច្ចភាពនៃការបញ្ជាក់របស់គាត់ថាត្រូវបានគេឃុំខ្លួននៅមន្ទីរស-២១។ ទាក់ទងនឹងបញ្ហានេះដែរ ឯកសារនានាដែលបាននិយាយពាក់ព័ន្ធនឹងគាត់ដែលមានប្រភពពីមន្ទី ស-២១ នោះ ក៏ជាកម្មវត្ថុដែលត្រូវធ្វើការដេញដោលផងដែរ[1]។ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ (“CPG-1”) បានលើកឡើងដោយគោរពថា បញ្ហាសំខាន់មួយដែលបានលើកឡើងយោងតាមសក្ខីកម្មរបស់លោក លី ហ៊រ តម្រូវឲ្យមានការពិនិត្យបន្ថែមទៀត ដោយអង្គជំនុំជម្រះដូចដែលបានលម្អិតជូនខាងក្រោម។

## II. សេចក្តីសន្និដ្ឋាន

២. បញ្ហាបឋមដែលលើកឡើងដោយអង្គជំនុំជម្រះសាលាដំបូង នៅក្នុងពេលវិវត្តន៍នៃកិច្ចដំណើរការនីតិវិធី មានការពាក់ព័ន្ធនឹងដើមកំណើតនៃឯកសារនានាដែលបង្ហាញដោយ លោក លី ហ៊រ ពេលដែលគាត់ជាប់ឃុំឃាំងនៅមន្ទីរ ស-២១[2]។ អង្គជំនុំជម្រះសាលាដំបូង បានរកឃើញថា ឯកសារនានានៅចំពោះមុខខ្លួនមិន “បង្ហាញភស្តុតាងថា ឯកសារទាំងនោះ [មក] ពីមន្ទី ស-២១ នោះទេ”[3]។ ដូចដែលបានប្រកាសដោយសហមេធាវីរបស់ CPG-1 លោក Alain Werner CPG-1 បានស្នើសុំ និងតាមរយៈនេះ មានបំណងផ្តល់ ការបំភ្លឺ

[1] ប្រតិចារឹក ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ ៥៧។

[2] ដូចឯកសារយោងខាងលើ ។

[3] ដូចឯកសារយោងខាងលើ ។

ពាក់ព័ន្ធនឹងប្រភពនៃឯកសារនេះ[4]។ សហមេធាវីរបស់ CPG-1 បានពន្យល់ដល់អង្គជំនុំជម្រះថា CPG-1 យល់ឃើញថា ឯកសារនានាភ្ជាប់ជាមួយនឹងពាក្យបណ្តឹងដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក លី ហ៊ រ ត្រូវបានមជ្ឈមណ្ឌលឯកសារកម្ពុជា យកបានមកពីមន្ទីរ ស-២១[5] ហើយដោយឡែក បានភ្ជាប់បែបនេះដែរជាមួយនឹងសេចក្តីប្រកាសរបស់លោក កេ សុបណ្ណការ (Ke Sopannaka) ដែលជាប្រធានសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដោយបានបញ្ជាក់ថា ច្បាប់ដើមនៃឯកសារ ដែលផ្តល់ជូនដើម្បីគាំទ្រដល់បណ្តឹងរបស់លោក លី ហ៊ រ ពិតជាត្រូវបានរកឃើញនៅមន្ទីរ ស-២១[6]។

៣. ទីពីរ បន្ទាប់ពីត្រូវបានគេផ្តល់ឱ្យនូវឱកាសបញ្ចេញយោបល់លើសក្ខីកម្មរបស់លោក លី ហ៊ រ រួចមក ជនត្រូវចោទបានសង្កេតឃើញថា មនុស្សដែលគេបានយោងនៅក្នុងឯកសារនានាតាមរយៈឈ្មោះ "អ៊ា ហ៊ រ" (Ear Haur) មិនអាចជាមនុស្សតែម្នាក់ជាមួយនឹងលោក លី ហ៊ រ នោះទេ ដោយសារតែបញ្ជីឈ្មោះអ្នកទោសដែលបានពិនិត្យសារឡើងវិញ និងចងក្រងដោយព្រះរាជអាជ្ញានោះ បង្ហាញថា បុរសដែលមានឈ្មោះថា "អ៊ា ហ៊ រ" (Ear Haur) ត្រូវគេប្រហារជីវិតនៅមន្ទីរ ស-២១ នៅពេលមួយក្នុងឆ្នាំ១៩៧៥ បាត់ទៅហើយ[7]។

៤. ដើម្បីបំភ្លឺអំពីអ្វីដែលឈានដល់ការយល់ច្រលំដែលកើតឡើងលើបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងបានស្នើសុំឱ្យលោកមេធាវី Alain Werner ធ្វើការពន្យល់ពាក់ព័ន្ធនឹងឈ្មោះអ្នកទោសដែលមាននៅក្នុងបញ្ជីឈ្មោះអ្នកទោស ដែលមានឈ្មោះដូចគ្នានឹងលោក លី ហ៊ រ ហៅ អ៊ា ហ៊ រ (Ear Hor)[8]។ លោក Werner បានពន្យល់ដល់អង្គជំនុំជម្រះថា គាត់មិនអាចផ្តល់យោបល់ថែមទៀតអំពីឈ្មោះ "អ៊ា ហ៊ រ" (Ear Haur) ដែលមាននៅក្នុងបញ្ជី

---

[4] ដូចឯកសារយោងខាងលើ, ទំព័រ ៥៥ ដល់៥៦។

[5] ដូចឯកសារយោងខាងលើ, ទំព័រ ៥៧ ដល់៥៨។

[6] ឧបសម្ព័ន្ធ ១។

[7] ដូចឯកសារយោងខាងលើ ទំព័រ ៨៤ ដល់៨៦, ៩៥ ដល់៩៧។

[8] ដូចឯកសារយោងខាងលើ ទំព័រ ៩៥ ដល់ ៩៦។

ឈ្មោះអ្នកទោសដែលគេបានប្រហារជីវិតហើយ ដោយមិនបានពិគ្រោះយោបល់ជាមួយនឹងកូនក្តីរបស់គាត់ជាមុននោះទេ[៩]។

៥. បន្ទាប់ពីបានពិភាក្សាជាមួយនឹងកូនក្តីរបស់ខ្លួន និងបានពិនិត្យឯកសារដោយយកចិត្តទុកដាក់រួច CPG-1 មានបំណងធ្វើការវិភាគដូចខាងក្រោម ដោយសង្ឃឹមថាអាចជួយបំភ្លឺដល់អង្គជំនុំជម្រះអំពីរឿងរ៉ាវកើតឡើងដែលមិនមានភាពច្បាស់លាស់ ពាក់ព័ន្ធនឹងអត្តសញ្ញាណរបស់លោក លី ហ៊ រ ហៅ អ៊ា ហ៊ រ។ CPG-1 បានសុំអភ័យទោសពីតុលាការដែលពុំមានលទ្ធភាពធ្វើការបំភ្លឺនៅក្នុងសវនាការតាមការស្នើសុំ។ ទោះបីជាបែបនេះក៏ដោយ ដោយសារតែសារៈសំខាន់នៃបញ្ហានេះ CPG-1 បានលើកឡើងដោយគោរពថា ឯកសារមួយនេះអាចជួយដល់អង្គជំនុំជម្រះសាលាដំបូងក្នុងការវាយតម្លៃលើភស្តុតាង ដែលមាននៅចំពោះមុខអង្គជំនុំជម្រះ។

៦. បញ្ជីឈ្មោះអ្នកទោសដែលបានពិនិត្យរួច ដែលប្រើដោយជនត្រូវចោទធ្វើជាមូលដ្ឋាននៃការសង្កេតរបស់ខ្លួននោះ បង្ហាញថា បុរសដែលមានឈ្មោះ "អ៊ា ហ៊ រ" (Ear Haur) ត្រូវបានចាប់ខ្លួនពីមន្ទីរម-១៣ ហើយបានចូលមកមន្ទីរស-២១ កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៧៥[10]។ នៅថ្ងៃខែឆ្នាំដដែល បុគ្គលម្នាក់ផ្សេងទៀតដែលមានឈ្មោះ អ៊ា ហ៊ រ (Ear Hor) ត្រូវបានសួរចម្លើយនៅមន្ទីរម-១៥[11]។

៧. លើសពីនេះទៀត ដូចដែលជនជាប់ចោទបានកត់សម្គាល់ឃើញ បញ្ជីឈ្មោះអ្នកទោសក៏សរសេរលម្អិតផងដែរថា បុរសដែលមានឈ្មោះថា "អ៊ា ហ៊ រ" (Ear Haur) ត្រូវគេ

---

[9] ដូចឯកសារយោងខាងលើ។

[10] រឿងក្តីជនជាប់ចោទ កាំង ហ្គេកអ៊ាវ លេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, បញ្ជីឈ្មោះអ្នកទោសមន្ទីរ ស-២១ ដែលបានពិនិត្យរួច E68,1 ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៩ ទំព័រ៨៦។

[11] រឿងក្តីជនជាប់ចោទ កាំង ហ្គេកអ៊ាវ លេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ជីវប្រវត្តិរបស់ អ៊ា ហ៊ រ (Ear Hor) E2/61.2, E2/61.2 ទំព័រ១៣។

ប្រហារជីវិតនៅមន្ទីរ ស-២១ ក្នុងឆ្នាំ១៩៧៥ បាត់ទៅហើយ[12]។ ទោះបីជាយ៉ាងណាក៏ដោយ CPG-1 ចង់ឲ្យអង្គជំនុំជម្រះធ្វើការយកចិត្តទុកដាក់ទៅលើឯកសារចំនួនពីរ ដែលបានផ្តល់ដើម្បីគាំទ្រដល់ពាក្យបណ្តឹងដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក លី ហ៊ រ ដែលមានការទទួលស្គាល់ពីជនជាប់ចោទថា ជាឯកសារយថាភូតដែលត្រឹមត្រូវតាមច្បាប់របស់មន្ទីរ ស-២១ ដែលចុះកាលបរិច្ឆេទឆ្នាំ១៩៧៦។ ឯកសារទីមួយ ចុះថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៦ គឺជាជីវប្រវត្តិលម្អិតស្តីពីសកម្មភាពរបស់ "អ៊ា ហ៊ រ" (Ear Hor)[13] ដែលជនជាប់ចោទបានប្រកាសថា ឯកសារនោះត្រូវបានសរសេរដោយបុគ្គលិកមន្ទីរស-២១ គឺ សមមិត្ត ណាក់ (Nak) នៅមន្ទីរ ស-២១[14]។ ឯកសារទីពីរ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៧៦ និងចុះថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦[15] ក៏មានការទទួលស្គាល់ពីជនជាប់ចោទស្រដៀងគ្នានេះដែរថា ឯកសារនេះត្រូវបានសរសេរដោយបុគ្គលិកមន្ទីរស-២១ គឺ សមមិត្ត ម៉ម ណៃ (Mam Nai)[16]។ លោក ម៉ម ណៃ បានបញ្ជាក់អំពីចំណុចនេះនៅពេលក្រោយមកទៀតក្នុងពេលផ្តល់សក្ខីកម្មកាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៩ ដោយបានផ្តល់សក្ខីកម្មថា គាត់គឺជាអ្នកសរសេរឯកសារនោះផ្នែកចម្លើយសារភាព[17]។ ហេតុដូច្នេះ វាបង្ហាញឲ្យឃើញថា ឯកសារទាំងពីរបានបង្ហាញដាច់ដោយឡែកពីគេថា បុគ្គលឈ្មោះ "អ៊ា ហ៊ រ" (Ear Hor) ត្រូវគេឃុំឃាំងនៅមន្ទីរ ស-២១ នៅឆ្នាំ១៩៧៦ បន្ទាប់ពីបុគ្គលឈ្មោះ "អ៊ា ហ៊ រ" (Ear Haur) ត្រូវគេសម្លាប់ចោលនៅឆ្នាំ១៩៧៥។

---

[12] រឿងក្តីជនជាប់ចោទ កាំង ហ្គេកអ៊ាវ លេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, បញ្ជីឈ្មោះអ្នកទោស មន្ទីរ ស-២១ ដែលបានពិនិត្យរួច E68,1 ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៩ ទំព័រ៨៦។

[13] រឿងក្តីជនជាប់ចោទ កាំង ហ្គេកអ៊ាវ លេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ជីវប្រវត្តិរបស់ អ៊ា ហ៊ រ (Ear Hor) E2/61.2, E2/61.2 ទំព័រ៤ ដល់១១។

[14] ប្រតិចារិក ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ ៨៤។

[15] រឿងក្តីជនជាប់ចោទ កាំង ហ្គេកអ៊ាវ លេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ជីវប្រវត្តិរបស់ អ៊ា ហ៊ រ (Ear Hor) E2/61.2, E2/61.2 ទំព័រ២។

[16] ប្រតិចារិក ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ ៨៣ ដល់៨៤។

[17] ប្រតិចារិក ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ ៤៣។ លោក ម៉ម ណៃ (Mam Nai) បានកត់សម្គាល់ឃើញយ៉ាងច្បាស់លាស់ថា គាត់ទទួលស្គាល់តែឯកសារសរសេរដែលស្តីពីផ្នែកចម្លើយសារភាពដែលជារបស់គាត់តែប៉ុណ្ណោះ។ គាត់បានលើកឡើងថា គាត់មិនមែនជាអ្នកសរសេរ "ផ្នែកសំណើសុំ" នៃឯកសារនោះទេ។

៨. ប្រសិនបើមានការចោទសួរ អំពីភាពត្រឹមត្រូវនៃកាលបរិច្ឆេទដែលមាននៅក្នុងបញ្ជីឈ្មោះអ្នកទោសដែលគេបានពិនិត្យរួចនោះ CPG-1 សូមស្នើដោយគោរពសុំឱ្យលើកយកការស្លាប់របស់បុគ្គលឈ្មោះ "អ៊ា ហ៊ រ" (Ear Haur) មកធ្វើការចោទសួរផងដែរ។ ដូច្នេះការពិចារណាអំពីខ្លឹមសារនៃជីវប្រវត្តិមន្ទីរ ស-២១ គឺជាការត្រឹមត្រូវ។ ជីវប្រវត្តិមន្ទីរ ស-២១ បង្ហាញថា "អ៊ា ហ៊ រ" (Ear Hor) ត្រូវគេឃុំខ្លួននៅមន្ទីរ ៤៤ ឬមិនអញ្ចឹងទេគេហៅថាមន្ទីរពេទ្យជំងឺផ្លូវចិត្តតាខ្មៅ[18] កន្លែងដែលលោក លី ហ៊ រ បានអះអាងថា គាត់ត្រូវគេឃុំខ្លួនអស់មួយរយៈ[19]។

៩. ផ្អែកតាមរឿងរ៉ាវខាងដើម នៅក្នុងការសន្និដ្ឋានដោយគោរពរបស់ CPG-1 នោះ វាច្បាស់ណាស់ថា លោក លី ហ៊ រ ហៅ អ៊ា ហ៊ រ (Ear Hor) ត្រូវគេឃុំខ្លួន និងត្រូវគេសួរចម្លើយកាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៧៥ នៅមន្ទីរ ១៥ រួចត្រូវគេបញ្ជូនទៅមន្ទីរ ៤៣ និងមន្ទីរ ៤៤ មុនពេលដែលជីវប្រវត្តិមួយត្រូវគេបង្កើតឡើងនៅមន្ទីរ ស-២១ កាលពីដើមឆ្នាំ ១៩៧៦។ ដូច្នេះហើយ គាត់មិនអាចជាបុគ្គលតែម្នាក់ដែលបានមកដល់មន្ទីរ ស-២១ កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៧៥ និងក្រោយមកទៀតត្រូវគេសម្លាប់ក្នុងឆ្នាំ១៩៧៥ ដោយយោងតាមបញ្ជីឈ្មោះអ្នកទោសដែលជនជាប់ចោទបានសំអាងនោះទេ ។ លោក លី ហ៊ រ ហៅ អ៊ា ហ៊ រ (Ear Hor) ត្រូវគេឃុំខ្លួននៅមន្ទីរស-២១ ដូចដែលបានផ្តល់សក្ខីកម្មយ៉ាងដូច្នោះមែន។

១០. ដើម្បីធ្វើឱ្យសក្ខីកម្មរបស់គាត់មានទម្ងន់នោះ ការពិតនៃវត្តមានរបស់គាត់នៅមន្ទីរ ស-២១ អាច និងគួរតែបញ្ចូលជាផ្នែកនៃកំណត់ហេតុ ពីព្រោះចំណុចនេះពាក់ព័ន្ធផ្ទាល់ទៅនឹងភាពដែលអាចជឿទុកចិត្តបានទាំងស្រុងរបស់សាក្សី។

---

[18] ប្រតិចារឹក ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ ៧៩ ដល់៨០។

[19] ដូចឯកសារយោងខាងលើ ទំព័រ ៩-១៣។

១១. តាមរយៈសេចក្ដីសន្និដ្ឋានរបស់ខ្លួន CPG-1 សង្ឃឹមថា នឹងជួយដល់អង្គជំនុំជម្រះក្នុងការឆ្លើយសំណួរដែលខ្លួនមិនអាចធ្វើនៅក្នុងតុលាការបាន និងដើម្បីបញ្ចប់នូវការយល់ច្រលំជុំវិញស្ថានភាពស្របច្បាប់របស់លោក លី ហ៊ រ ក្នុងនាមជាអ្នកនៅរស់រានមានជីវិតពីមន្ទីរស-២១ ព្រមទាំងយថាភាពនៃឯកសារដែលបានបង្ហាញដល់គាត់។

III. **សំណើសុំ**

១២. ដើមបណ្ដឹងរដ្ឋប្បវេណី ក្រុម១ សូមស្នើដោយក្ដីគោរព សុំឱ្យអង្គជំនុំជម្រះសាលាដំបូងមេត្តាសរសេរចូលក្នុងកំណត់ហេតុថា លោក លី ហ៊ រ ត្រូវបានឃុំខ្លួននៅមន្ទីរស-២១ នៅឆ្នាំ១៩៧៦ និងថា ឯកសារនានាដែលបានភ្ជាប់ជាមួយនឹងពាក្យបណ្ដឹងដើមបណ្ដឹងរដ្ឋប្បវេណីគឺជាកម្មសិទ្ធិរបស់លោក លី ហ៊ រ និងត្រូវបានរកឃើញនៅមន្ទីរ ស-២១។

សូមដាក់ជូនដោយក្ដីគោរពពី
សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី(ក្រុម១),
ចុះហត្ថលេខានៅរាជធានីភ្នំពេញ នាថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩

| (already signed) | (already signed) | (already signed) | (already signed) |
|---|---|---|---|
| ទី ស្រ៊ុនណា | Alain Werner | Krim A.A. Khan | Brianne McGonigle |